រាជធានីភ្នំពេញ ,ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៣១ សសរ**

**ស្តីពីការបង្កើតគណៈកម្មការជួសជុលបុរីកីឡា**

**រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មការជួសជុលបុរីកីឡាលេខ ១២៥ សសរ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើសុំផ្លាស់ប្តូរសមាសភាពគណៈកម្មការជួសជុលបុរីកីឡាលេខ ១១៥៣ អយក.រប ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩ របស់ក្រសួងអប់រំ យុវជន និង កីឡា

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការជួសជុលបុរីកីឡា ដែលមានសមាសភាពកែសំរួលដូចតទៅ :

១-ឯកឧត្តម មី សាមឌី ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សហប្រធាន

២-ឯកឧត្តម ម៉ុក ឋន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជា សហប្រធានសមាជិកគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ។

៣-ឯកឧត្តមម៉ិន ម៉ុយ អគ្គហិរញ្ញិកនៃគណៈកម្មាធិការអូឡាំពិកកម្ពុជា អគ្គលេខាធិការ

៤-លោកជំទាវ ស៊ិន ស៊ីរី តំណាងទីស្តីការគណៈរដ្ឋមន្ត្រី

៥-ឯកឧត្តម ម៉ូ ជុំសើរ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិកគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អគ្គហិរញ្ញិករង

៦-លោក សូ សាមុត អនុប្រធានទទួលបន្ទុកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា សមាជិក

៧-លោក មាស សារិន អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិក

៨-លោក ជា សឿន ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋក្រសួងអប់រំ យុវជន និងកីឡា សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

- សិក្សាវាយតំលៃស្ថានភាពសំណង់ក្នុងបុរីកីឡា និង លើកគំរោងជួសជុល ដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័ត ។
- ពិភាក្សា សំរបសំរួលឥណទានសំរាប់ ប្រើប្រាស់ក្នុងការជួសជុលបុរីកីឡា ជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិន ។

- ពិភាក្សា សំរបសំរួលជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីជ្រើសរើសរកសហគ្រិនដែលមានស្នាដៃល្អក្នុងការងារសំរាប់ជួលជុលប្អូរីកីឡា ។
- ត្រួតពិនិត្យដំណើរការជួសជុលប្អូរីកីឡា និង រាយការណ៍អំពីការងារសំរេចបាន ជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មាការមួយចំនួន ដើម្បីជាជំនួយការងារ និងមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ។

ប្រការ ៤ : សមាជិករបស់គណៈកម្មាការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៥ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹង សេចក្តីសំរេចនេះទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣២ សសរ

## ស្តីពីការបន្ថែមសមាសភាពនៅក្នុងគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ០៧/សសរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- តាមសំណើប្រធានគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា